<u>សំនួរដែលគេតែងតែសួរជារឿយៗអំពីយុវជនដែលប្រថុយ</u>

<u>គ្រោះថ្នាក់</u>

# **ARY FAQ's:**

តើមូលហេតុអ្វីបានជាខ្ញុំគួរតែទៅយកបណ្តឹងនៃយុវជនដែលប្រថុយគ្រោះថ្នាក់?

ដើម្បីឲ្យបានទទួលជំនួយនិងការគាំទ្រពីតុលាការយុវជននៅក្នុងការរក្សានូវការថែទាំព្យាបាលនិងការគ្រប់គ្រងកូនក្មេងនិងជួយក្នុងការដោះស្រាយនូវជម្លោះនៅក្នុងគ្រួសារក្រោយពីមានការព្យាយាមរកមធ្យោបាយក្នុងការជួយជ្រោមជ្រែងផ្សេងទៀតក្រៅពីការជួយជ្រោមជ្រែងរបស់តុលាការ។

តើយុវជនរបស់ខ្ញុំមានគុណសម្បត្តិទទួលឬទេ?

តាមអត្ថន័យរបស់ច្បាប់ យុវជនដែលមានការប្រថុយគ្រោះថ្នាក់គឺជាក្មេងក្រោមអាយុ១៨ ឆ្នាំដែលបានបំពេញទៅតាមសេចក្តីតំរូវមួយក្នុងចំណោមសេចក្តីតំរូវដូចខាងក្រោមនេះ:

១. បានបាត់ខ្លួនពីផ្ទះបានយ៉ាងតិចបំផុត៧២ម៉ោងជាប់ដោយមិនមានការយល់ព្រមពីមាតាបិតាឬក៏

២. មិនអាចមានការគ្រប់គ្រងពីមាតាបិតាបានទៀតឡើយ ហើយអាកប្បកិរិយារបស់ក្មេងនោះធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាព, សន្តិសុខ ឬសុខមាលភាពរបស់ក្មេងនោះឬដល់មនុស្សដ៏ទៃណាមួយ ឬក៏

៣. មានបញ្ហាខាងកាឬប្រមាថលើគ្រឿងស្រវឹងឬគ្រឿងញៀនហើយដែលមិនមានការចោទ ប្រកាន់ខាងបទព្រហ្មទណ្ឌដែលទាក់ទងទៅនឹងការប្រមាថលើគ្រឿងស្រវឹងឬគ្រឿងញៀនដែលតុលាការកំពុងដោះស្រាយ។

*ច្បាប់បានតំរូវឲ្យអ្នកដែលធ្វើបណ្តឹងទាមទារព្យាយាមឲ្យមានការធ្វើ*

*អន្តរាគមន៍ដើម្បីធ្វើឲ្យអាកប្បកិរិយារបស់ក្មេងបានប្រសើរមុនការដាក់ពាក្យសុំសំណើរខាងផ្នែកយុវជនដែលប្រថុយគ្រោះថ្នាក់។ឧទាហរណ៍:ការជួយផ្តល់ការឲ្យឱវាទដល់បុគ្គល/គ្រួសារឬការព្យាបាលខាងផ្នែកគ្រឿងញៀនឬគ្រឿងស្រវឹង។*
*បើសិនជាលោកអ្នកមិនទាន់មានការព្យាយាមរកមធ្យោបាយផ្សេងក្នុងការជួយជ្រោមជ្រែងក្រៅពីតុលាការទេ FRS អាចសុំឲ្យមានការឲ្យឱវាទ១២ម៉ោនៅក្នុងផ្ទះ(ចូរមើលលេខខាងក្រោម)។*

តើនរណាអាចដាក់ពាក្យបណ្តឹងទាមទារបាន?

មានតែមាតាបិតារបស់ក្មេងទេដែលអាចដាក់ពាក្យបណ្តឹងទាមទារខាងផ្នែកយុវជនដែលប្រថុយគ្រោះថ្នាក់បាន។ "មាតាបិតា" តាមអត្ថន័យគឺជាមនុស្សដែលមានសិទ្ធិស្របនឹងច្បាប់ក្នុងការគ្រប់គ្រងកូនហើយដោយមានរាប់បញ្ចូលទាំងអ្នកគ្រប់គ្រងកូនឬអ្នកអាណាព្យាបាល។

តើខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីធ្វើឲ្យដំណើរការបានចាប់ផ្តើម?

ចូរទាក់ទងមកការិយាល័យនៃសេវាខាងផ្នែកផ្សះផ្សារឿងគ្រួសារ(FRS)ឬនៅឯក្រសួង

សង្គមកិច្ចនិងសុខមាលភាពហើយស្នើសុំនូវការណាត់ជួបមួយសំរាប់ការផ្តល់ព័តមានចុះឈ្មោះនិងការប្រមាណមើល។ នៅទីបញ្ចប់នៃការប្រជុំនេះអ្នកធ្វើការកាន់សំណុំរឿងខាង
ការទទួលព័តមានចុះឈ្មោះនឹងរៀបចំធ្វើការប្រមាណមើលដល់គ្រួសារមួយ។ ចូរស្នើសុំនូវ
ក្រដាសថតចម្លងមួយដែលស្តីអំពីការធ្វើការប្រមាណមើលដល់គ្រួសារមួយហើយដាក់ភ្ជាប់ជាមួយនឹងពាក្យបណ្តឹងសុំសំណើខាងផ្នែកយុវជនដែលប្រថុយគ្រោះថ្នាក់មុនធ្វើការដាក់ ពាក្យបណ្តឹង។ តុលាការត្រូវតែមាននូវក្រដាសថតចម្លងមួយដែល
ស្តីអំពីការធ្វើការប្រមាណមើលដល់គ្រួសារមុនចាត់ការធ្វើបណ្តឹងទាមទារនោះ។

<u>*បើសិនជាលោកអ្នកមិនទាន់បានទទួលនូវការធ្វើការប្រមាណមើលដល់គ្រួសារឲ្យបានទាន់ពេលសម្រាប់ពេលធ្វើសវនាការរកការណ៏ពិតទេ សវនាការរកការណ៏ពិតនោះអាចនឹងត្រូវបន្តទៅថ្ងៃក្រោយ។*</u>

សេវាខាងផ្នែកផ្សះផ្សារឿងគ្រួសារ (*FRS*)

១-៨០០-៦០៩-៨៧៦៤ ពេលថ្ងៃ ពីម៉ោង៨ព្រឹកទៅម៉ោង៤៣០ល្ងាច

១-៨០០-៥៦២-៥៦២៤ ក្រោយម៉ោងធ្វើការ ពីម៉ោង៤៣០ល្ងាចទៅម៉ោង៨ព្រឹក

តើខ្ញុំត្រូវដាក់ពាក្យបណ្តឹងទាមទារនៅទីណា?

ពាក្យបណ្តឹងទាមទារត្រូវធ្វើនៅឯតុលាការយុវជននៅក្នុងករិយាល័យក្រឡាបញ្ជីតុលាការ
(1211 E. Alder, Seattle)ឬក៏នៅឯមណ្ឌលយុត្តិធម៍ប្រចាំភូមិភាគ Regional Justice Center (401– 4th Ave., N. Kent )។
ការប្តឹងសុំអាចដាក់នៅកន្លែងណាមួយក៏បានដែរប៉ុន្តែសវនា
ការកើតមានឡើងនៅឯសាលាកាត់ក្តីដែលទាក់ទងទៅនឹងលេខស៊ីពខូតដែលមាតាបិតារស់នៅ។ តាមធម្មតាបណ្តឹងក្តីនៅស៊ីអាថុលតំបន់ប៉ែកខាងកើត និងតំបន់យើងខាង
ជើងនឹងត្រូវគេស្តាប់នៅស៊ីអាថុលហើយបណ្តឹងក្តីនៅតំបន់យើងខាងត្បូងនឹងត្រូវគេស្តាប់នៅខិន។

តើមានអស់ថ្លៃអ្វីទេ?

មិនមានការបង់ថ្លៃអ្វីទេក្នុងការដាក់ពាក្យបណ្តឹងឬសម្រាប់កាឬធ្វើការប៉ាន់ប្រមាណអំពីគ្រួសារ។ មាតាបិតាត្រូវតែទទួលខុសត្រូវខាងផ្នែកប្រាក់កាស់សម្រាប់បង់ថ្លៃដែលទាក់ទងនឹង ផែនការនៃដីការតុលាការ(ការឲ្យឱវាទ,
ការប៉ាន់ប្រមាណ/ការរៀនព្យាបាលអំពីគ្រឿង
ញៀន/គ្រឿងស្រវឹង, ការប៉ាន់ប្រមាណមើលសុខភាពខួរក្បាល។ល។)។ លោកអ្នកអាចនឹង
ត្រូវបង់ប្រាក់សម្រាប់មេធាវីដែលត្រូវបានតែងតាំងអោយដំណាងកូនរបស់លោកអ្នក។ សម្រាប់
ពត៏មានថែមទៀត លោកអ្នកអាចទាក់ទងទៅ ការិយាល័យមេធាវីការពារក្តីសាធារណ: តាមលេខ
ទូរស័ព្ទ ២0៦-២៩៦-៧៦៦២។

*តើខ្ញុំអាចទាក់ទងនឹងអ្នកណាបានបើសិនជាខ្ញុំត្រូវការជំនួយក្នុងដំណើរនៃការ*
*ប្តឹងសុំ*?

សម្រាប់ព័តមានជាបន្ថែមអំពី <u>ការដាក់ពាក្យសុំប្តឹងទាមទារ</u>, សូមទាក់ទងមក
ម៉ូណា ហ្គូននិន(mona.johnen@kingcounty.gov)បុគ្គលិកជំនួយការខាងផ្នែកកម្មវិធីខាងផ្នែកយុវជនដែលប្រថុយគ្រោះថ្នាក់នៅលេខ២០៦-២០៥-៩៧៣២។

សម្រាប់សំនួរអំពីសំណុំរឿងដែលបានដាក់រួចហើយឬកំពុងធ្វើនៅពេលថ្មីៗនេះសូម ទាក់ទងមកអ្នកកាន់កាប់សំណុំរឿងនៅឯកន្លែងដែលលោកអ្នកមកបង្ហាញខ្លួននៅឯសវនាការរបស់តុលាការ។

មណ្ឌលយុត្តិធម៌ប្រចាំភូមិភាគ(ខិន) Regional Justice Center (Kent)

អេមុី អែនទ្រី (amy.andree@kingcounty.gov), (២០៦) ២០៥-២៥៧៨
សាលាកាត់ក្ដីយុវជន(សុីអាថុល) Juvenile Courthouse (Seattle)

ឃែរិន ឆាបមិន (karen.chapman@kingcounty.gov), (២០៦) ២០៥-៩៧១៦

តើខ្ញុំត្រូវការឱ្យដំណឹងទៅយុវជនអំពីថ្ងៃខែឡើងតុលាការដោយវិធីណា?

ដើម្បីយកមកឱ្យ ឱ្យបានត្រឹមត្រូវ មនុស្សម្នាក់ដែលមិនចូលខាងណា(មនុស្សម្នាក់ក្រៅពី មាតាបិតា)អាយុលើសពី១៨ឆ្នាំត្រូវតែបានប្រគល់អោយដោយផ្ទាល់ដៃទៅភាគីមួយនូវ ឯកសារថតចម្លងដែលមកចំពោះមុខតុលាការ។ បន្ទាប់ពីអ្នកដែលយកឯកសារតុលាការ ប្រគល់ទៅឱ្យភាគីប្រឆាំងហើយអ្នកនោះគួរតែបំពេញក្រដាស់ប្រកាស់អំពីសេវ៉ា(Decla ration of Service)។ ក្រដាស់បំពេញនោះតម្រូវឱ្យអ្នកដែលបំរើខាងការយកក្រដាស់ទៅ ប្រគល់នោះ(Server)ធ្វើសេចក្ដីថ្លែងក្រោមសម្បថទៅឱ្យតុលាការ(ក្រោមសម្បថ)ដាក់ថាគាត់បានយកក្រដាស់ស្នាមតុលាការចាំបាច់ទៅប្រគល់ឱ្យភាគីនោះ។ អ្នកដែលបំរើខាង ការយកក្រដាស់ទៅប្រគល់នោះ(Server)គួរតែដាក់ថ្ងៃខែនិងចុះនូវហត្ថលេខាលើក្រដាស់ ប្រកាស់អំពីសេវ៉ា (Declaration of Service)នៅខាងក្រោម ហើយយកមកឱ្យភាគីដែលស្នើសុំសេចក្ដីបម្រើរបស់គាត់។ ក្រដាស់បំពេញនោះហៅថា: "ភស្តុតាងនៃសេវ៉ា" **"Proof of Service"** ហើយត្រូវនាំយកក្រដាស់នោះមកឯសវនាការ។

ដោយសារនេះជាដំណើរការនៅតុលាការ តើមានមេធាវីចូលរួមទេ?

កូនក្មេងត្រូវបានតុលាការតែងតាំងឱ្យមានមេធាវីតំណាងគ្រប់ពេលធ្វើសវនាការដោយស្វ័យប្រវត្តិតែម្ដង។ នៅក្រោមការសុំប្ដឹងខាងផ្នែកARYមាតាបិតាមិនមានសិទ្ធិឱ្យតុលាការតុលាការតែងតាំងឱ្យមានមេធាវីតំណាងបានទេទោះបីជាមានសេចក្ដីត្រូវការខាងថវិការយ៉ាងណាក៏ដោយ។ មាតាបិតាតែងតែមានសិទ្ធិរកមេធាវីដោយខ្លួនឯងបានដោយគេជាអ្នកចេញថ្លៃដោយខ្លួនឯង។

*តើមានអ្នកបកប្រែចាំជួយឬទេបើសិនមានអ្នកណាម្នាក់មិនចេះនិយាយភាសាអង់គ្លេស?*

បើសិនមានអ្នកណាម្នាក់ត្រូវការអ្នកបកប្រែនៅពេលឡើងតុលាការធ្វើសវនាការមួយ ចូរប្រាប់បុគ្គលិកនៃការិយាល័យក្រឡាបញ្ជីនៅពេលដាក់ពាក្យបណ្ដឹង។ តុលាការជាន់ខ្ពស់ ប្រចាំតំបន់យើងនឹងចេញថ្លៃឱ្យសម្រាប់ការបម្រើរបស់អ្នកបកប្រែទាំងអស់។

*តើតុលាការអាចចេញដីការអំពីអ្វីខ្លះបាន?*

បើសិនតុលាការយល់ឃើញថាយុវជនជាអ្នកដែលប្រថុយគ្រោះថ្នាក់ តុលាការអាចចេញជា ដីការតម្រូវថាឱ្យ:

យុវជនត្រូវ

- ទៅរៀនដោយមិនមានការឈប់ដោយឥតមានការអនុញ្ញាត្តិ, ការឃឺតយ៉ាវ ឬត្រូវទទួលការព្យួរទោសដោយសារមកពីកិរិយាមាយាទ
- ធ្វើការប្រណាមើលអំពីសារធាតុញៀននិងសុរា
- ធ្វើការប្រមាណមើលអំពីផ្លូវចិត្ត, គំនិត និង សតិ
- ចុះហត្ថលេខាឲ្យព័តមានដែលអនុញ្ញាត្តិឲ្យតុលាការ មាតាបិតា និងមេធាវី ទទួលនូវលទ្ធផលផ្សេងៗ
- ប្រគល់ឲ្យគេយកទឹកនោមទៅធ្វើវិភាគដោយមិនឲ្យដឹងជាមុន
- ចូរកុំប្រើប្រាស់ឬមានថ្នាំញៀនដែលមិនមានក្រដាសវេជ្ជៈបញ្ជាឬសុរា
- ចូរគោរពដល់បំរាមគោចរ
- ចុះឈ្មោះព្រមទាំងចូលរួមនៅក្នុងការឲ្យឱវាទមួយទល់មួយឬជាមួយក្រុមគ្រួសា
- រស់នៅជាមួយមាតាបិត
- ចូរកុំឲ្យមានការទាក់ទងជាមួយ...
- មិនឲ្យមានមនុស្សឯទៀតចូលមកក្នុងផ្ទះរបស់មាតាបិតាដោយមិនមានសេចក្តីអនុញ្ញាត្តិ
- ចូរកុំឲ្យមានការប្រមាថដោយកាយវិការឬដោយពាក្យសំដីទៅលើមនុស្សឬទ្រព្យសម្បត្តិ

មាតាបិតាត្រូវ

- ដឹងច្បាស់ថាមានការចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីសាលារៀន
- ចាត់ចែងនូវការណាត់ជួប ធ្វើការប្រមាណមើលអំពីរឿងផ្សេងៗសម្រាប់យុវជន
- បិទប្រកាសនូវការសរសេរជាលាយលក្ខ័អក្សរអំពីវិន័យ, កិច្ចការដែលតម្រូវឲ្យ
  មាននៅក្នុងផ្ទះសម្បែង
- ចុះឈ្មោះព្រមទាំងចូលរួមនៅក្នុងការឲ្យឱវាទមួយទល់មួយឬជាមួយក្រុមគ្រួសារឬថ្នាក់រៀនអំពមុខងារជាមាតាបិតា
- ចូរកុំឲ្យមានការប្រមាថដោយកាយវិការឬដោយពាក្យសំដីទៅលើមនុស្សឬទ្រព្យសម្បត្តិ

*តើតុលាការមិនអាចចេញដីការអំពីអ្វីខ្លះបាន?*

រដ្ឋវ៉ាស៊ីនតោនជារដ្ឋដែលមិនអាចបង្ខំឲ្យមានការចូលគេងព្យាបាលឡើយ។ដូច្នេះតុលាការមិនអាចបញ្ជាឲ្យមានការចូលគេងព្យាបាលនៅក្នុងមន្ទីរព្យាបាលផ្សេងៗបានឡើយ។

*តើមានការអ្វីកើតឡើងបើសិនភាគីមួយមិនធ្វើតាមដីការរបស់តុលាការ?*

ការខកខានមិនបានធ្វើតាមដីការរបស់តុលាការរបស់ភាគីណាមួយ គឺជាការបំពានទៅលើដីការរបស់តុលាការ។ ការបំពានទៅលើដីការរបស់តុលាការត្រូវឲ្យមានសេចក្តីរាយការណ៍ទៅតុលាការតាមរយៈការដាក់ពាក្យបណ្តឹងដែលស្តីអំពីការបំពានទៅលើដីការរបស់តុលាការ។ ពាក្យបណ្តឹងដែលស្តីអំពីការបំពានទៅលើដីការរបស់តុលាការអាចធ្វើទៅបានដោយមាតាបិតា, កូនក្មេងឬមនុស្សម្នាក់/អង្គការមួយដែលមានការគ្រប់គ្រងលើកូនក្មេងនោះ។ បើសិនជាតុលាការការរកឃើញថាមានការបំពាននៅឯ*សវនាការអំពីរឿងការបំពានទៅលើដីការរបស់តុលាការ*នោះតុលាការប្រហែលជាដាក់ទណ្ឌកម្មដោយបង្ខំដូចជាការស្រាវជ្រាវសរសេរក្រដាស់ស្នាមឬចំនួនម៉ោងនៃការបម្រើសហគន៏ជាជាងការជាប់ឃុំឃាំងនៅក្នុងមន្ទីរឃុំឃាំងដើម្បីអោយមានសន្តិសុខ, ដូចជាការធ្វើការដោយប្រើកម្លាំងកាយ នៅក្រៅអាគារឬជាប់ឃុំឃាំងរហូតដល់ទៅ៧ថ្ងៃនៅក្នុងមន្ទីរឃុំឃាំងយុវជនឬបង់ប្រាក់ពិន័យរហូតដល់ទៅ$១០០ ទទួលទណ្ឌកម្មផ្សេងៗផ្សំជាមួយគ្នា។

ចូរកុំចាំដល់ពេលកំណត់ធ្វើសវនាការសើរើសំណុំរឿងដើម្បីរាយការណ៍អំពីការបំពានទៅលើដីការតុលាការឡើយ។ការណាត់ជួបជាមួយអ្នកចាត់ចែងសំណុំរឿងជាការចាំបាច់មួយក្នុងការដាក់ពាក្យបណ្តឹងទាមទារដែលស្តីអំពីការបំពានទៅលើដីការរបស់**តុលាការ** ។

តើយើងគួរតែធ្វើយ៉ាងណាបើសិនជាស្ថានការរបស់យើងជាស្ថានការបន្ទាន់/មានវិបត្តិហើយយើងមិនអាចចាំដល់ពេលឡើងតុលាការបានឡើយ។

**គ្រោះថ្នាក់ដែលនឹងកើតឡើង:** ចូរទូរសព្ទ័ទៅលេខ “៩១១”

ខ្សែរទូរស័ព្ទ២៤ម៉ោងសម្រាប់ពេលមានវិបត្តិប្រចាំតំបន់យើង

១-៨៦៦-៤**CRISIS**